# ឯកសារសង្ខេបអំពីដៃគូយុទ្ធសាស្ត្រអនុវត្តន៍កម្មវិធី
# ផ្នែកពិការភាព

## សង្ខេបគម្រោង

អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍបរិយាបន្ន (PAfID) គឺជាអង្គការដៃគូដែលកំពុងអនុវត្តកម្មវិធី ACCESS 2 ។ អង្គការPAfID គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជាដែលធ្វើការលើពិការភាព និងការអភិវឌ្ឍន៍ដើម្បីធ្វើឱ្យសង្គមមានបរិយាបន្នដោយគ្មាននរណាម្នាក់ត្រូវបានទុកចោល។ កម្មវិធីរបស់ PAfID នឹងរួមចំណែកជាមួយកម្មវិធី ACCESS 2 ដើម្បីពង្រឹងបន្ថែមលើបរិយាបន្នពិការភាព បង្កើនការយល់ដឹង និងកសាងសមត្ថភាពដល់អ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិដែលជាកត្តាសំខាន់សម្រាប់ការផ្លាស់ប្តូរកាន់តែប្រសើរ និងប្រកបដោយនិរន្តរភាព។ កម្មវិធីផ្តោតលើការពង្រឹងសមត្ថភាពរបស់អង្គការជនមានពិការភាព (OPDs) លើកកម្ពស់ការបញ្ជ្រាបពិការភាពលើគ្រប់វិស័យ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ព័ន្ធដូចជា៖ ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត (P-DAC) ស្រុក/ខណ្ឌ ឃុំ/សង្កាត់ អង្គការជនមានពិការភាព អង្គការអភិវឌ្ឍន៍មិនមែនរដ្ឋាភិបាលនៅកម្ពុជា និងវិស័យឯកជន។ តាមរយៈការកសាងសមត្ថភាពអង្គការជនមានពិការភាព គម្រោងនេះ នឹងលើកកម្ពស់ការចូលរួមយ៉ាងសកម្មរបស់ជនមានពិការភាពនិង/ ឬតំណាងរបស់ពួកគេនៅក្នុងផែនការ និងដំណើរការពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

## លទ្ធផលរំពឹងទុករបស់គម្រោង

លទ្ធផលគម្រោងទី១៖ អង្គការជនមានពិការភាព និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធមានសមត្ថភាពកាន់តែប្រសើរ ក្នុងការធ្វើការដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងស្វែងរកមតិគាំទ្រដើម្បីសិទ្ធិរបស់ជនមានពិការភាព។

លទ្ធផលគម្រោងទី២៖ ជនមានពិការភាពមានលទ្ធភាពទទួលបានសេវា ប្រើប្រាស់សេវា និងកម្មវិធីសាធារណៈកាន់តែប្រសើរ តាមរយៈបង្កើនសមត្ថភាពកាន់តែប្រសើររបស់អង្គការជនមានពិការភាព ដើម្បីគាំទ្រដល់ការពង្រឹងប្រព័ន្ធបញ្ជូន និងការលើកកម្ពស់ការបញ្ជ្រាបពិការភាពលើគ្រប់ទាំងវិស័យ។

លទ្ធផលគម្រោងទី៣៖ បង្កើនចំណេះដឹងតាមវិស័យ និងលើកកម្ពស់កិច្ចសហការពហុវិស័យលើការធ្វើបរិយាបន្នពិការភាព រួមទាំងការឆ្លុះបញ្ចាំង ការរៀនសូត្រ និងការចែករំលែក។

| សកម្មភាពសំខាន់ៗ |
|---|
| យើងចង់ឃើញជនមានពិការភាពមានលទ្ធភាពទទួលបានសេវាប្រើប្រាស់ និងកម្មវិធីសាធារណៈកាន់តែប្រសើរ។ កម្មវិធីនេះនឹងសម្រេចទៅបានតាមរយៈការធ្វើសកម្មភាពសំខាន់ៗ ដើម្បីបង្កើនសមត្ថភាពរបស់អង្គការជនមានពិការភាព ដើម្បីគាំទ្រដល់ការពង្រឹងប្រព័ន្ធបញ្ជូន និងការលើកកម្ពស់ការបញ្ជ្រាបពិការភាពលើគ្រប់វិស័យ រួមទាំងការភ្ជាប់ផ្នែកតម្រូវការនិងផ្នែកផ្គត់ផ្គង់។ យើងនឹងលើកកម្ពស់ការទទួលបានកម្មវិធីកិច្ចគាំពារសង្គមផងដែរ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គការជនមានពិការភាពជាដៃគូ និងក្រសួង/នាយកដ្ឋានពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។<br><br>ការធ្វើសកម្មភាព ជាក់លាក់សំខាន់ៗមួយចំនួនត្រូវបានគ្រោងក្នុងផែនការទុកដូចជា៖ ការផ្តល់នូវការអភិវឌ្ឍសមត្ថភាព និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដល់អង្គការជនមានពិការភាព  រៀបចំវេទិការៀនសូត្រ/វេទិកាផ្សេងៗ ដើម្បីលើកកម្ពស់បរិយាបន្នពិការភាព និងកិច្ចសហការជាមួយដៃគូ  គាំទ្រធនធានចាំបាច់ដល់អង្គការជនមានពិការភាពដើម្បីអនុវត្តកម្មវិធីនិងសេវារបស់ពួកគេដូចជា៖ ផ្តល់ការយល់ដឹងដល់សហគមន៍គោលដៅ បញ្ជូនទៅរកសេវា ស្វែងរកមតិគាំទ្រ និងឆ្លើយតបទៅនឹងតម្រូវការរបស់ជនងាយរងគ្រោះ។ អង្គការជនមានពិការភាពជាដៃគូនឹងត្រូវបានគាំទ្រដើម្បីដើរតួនាទីយ៉ាងមានប្រសិទ្ធិភាពជាស្ពានភ្ជាប់រវាងសហគមន៍ និងអាជ្ញាធរពាក់ព័ន្ធដើម្បីកំណត់រកបញ្ហា និងដាក់បញ្ចូលសំឡេងរបស់ជនដែលងាយរងគ្រោះទៅក្នុងផែនការអភិវឌ្ឍន៍។ |
| **អ្នកទទួលផល** |
| • អង្គការជនមានពិការភាព៖ អង្គការជនមានពិការភាពនឹងត្រូវបានគាំទ្រលើការអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេ។ យើងនឹងធ្វើការជាមួយពួកគេតាមមធ្យោបាយមួយដែលមានការចូលរួមក្នុងការកំណត់ភាពខ្លាំង និងផ្នែកដែលត្រូវពង្រឹងបន្ថែមបន្ទាប់មកបង្កើតផែនការកែលម្អ។ អង្គការជនមានពិការភាពនឹងត្រូវបានគាំទ្រក្នុងការអភិវឌ្ឍន៍កម្មវិធីដោយឆ្លុះបញ្ចាំងពីតម្រូវការរបស់ជនមានពិការភាព និងការកសាងសមត្ថភាពដើម្បីឆ្លើយតបទៅអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា។<br>• ជនមានពិការភាព រួមទាំងស្ត្រី និងក្រុមជនជាតិដើមភាគតិចនឹងទទួលបានអត្ថប្រយោជន៍តាមរយៈការបង្កើនការយល់ដឹងអំពីសេវានិងកម្មវិធី ព្រមទាំងការវិភាគអំពីគម្លាតដែលមាន។ កិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អយន្តការបញ្ជូន និងផ្តល់លទ្ធភាពឱ្យជនមានពិការភាពជាច្រើនទៀត រួមទាំងក្រុមជនជាតិដើមភាគតិចអាចទទួលបានសេវាដែលអ្នកទាំងនោះមានសិទ្ធិទទួល ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាបន្នសង្គម សុខុមាលភាព សេចក្តីថ្លៃថ្នូរ និងលើកកម្ពស់ជីវភាពរស់នៅរបស់គាត់។ |
| **តំបន់គោលដៅ** |
| • សៀមរាប៖ ស្រុកបន្ទាយស្រី និងស្រុកប្រាសាទបាគង |

| |
|---|
| • កំពង់ចាមៈ ស្រុកបាធាយ ស្រុកជើងព្រៃ និងស្រុកព្រៃឈរ<br>• កំពង់ស្ពឺៈ ក្រុងច្បារមន ស្រុកសំរោងទង និងស្រុកឧដុង្គ<br>• បាត់ដំបងៈ ក្រុងបាត់ដំបង និងធ្វើដំណើរទៅកាន់ស្រុកនានា អាស្រ័យលើទីតាំងដែលមានសមាជិកពិការខួរឆ្អឹងខ្នង |

| **ដៃគូអនុវត្តគម្រោង** | |
|---|---|
| • អង្គការតំណាងជនពិការជួយខ្លួនឯងស្រុកបាធាយ (RSDOB-ស្រុកបាធាយ/កំពង់ចាម) | • នាយកប្រតិបត្តិៈ លោក សយ សុខន<br>អ៊ីម៉ែលៈ sokhorn.rsdob@gmail.com<br>លេខទំនាក់ទំនងៈ ០១៦ ៩៥១ ១៩២ |
| • អង្គការតំណាងជនពិការខេត្តកំពង់ស្ពឺ | • នាយកប្រតិបត្តិៈ លោក អ៊ូ សំបូរ<br>អ៊ីម៉ែលៈ គ្មាន<br>លេខទំនាក់ទំនងៈ ០១៦ ៩៣១ ៩៧៤ |
| • អង្គការតំណាងជនពិការខេត្តសៀមរាប(OPD-សៀមរាប) | • នាយិកាប្រតិបត្តិៈ លោកស្រី កាយ ស្រីអន<br>អ៊ីម៉ែលៈ គ្មាន<br>លេខទំនាក់ទំនងៈ ០៨៨ ៧៨៤ ៨០៦១ |
| • សមាគមជនពិការខួរឆ្អឹងខ្នងកម្ពុជា (SCIAC) បាត់ដំបង | • នាយិកាប្រតិបត្តិៈ កញ្ញា ជាតិ សុខា<br>អ៊ីម៉ែលៈ sokhacheati@yahoo.com<br>លេខទំនាក់ទំនងៈ ០៩៩ ៧២៩ ៨៩៩ |

| **រយៈពេលអនុវត្តគម្រោង** |
|---|
| ចាប់ផ្តើមគម្រោងៈ ខែមករា ឆ្នាំ២០២៤ ដល់ ខែមិថុនា ឆ្នាំ២០២៨ |

| **ព័ត៌មានទំនាក់ទំនង** | |
|---|---|
| អង្គការ PAfID<br>លោក ខេង វីរៈ<br>នាយកប្រតិបត្តិ<br>ទូរស័ព្ទៈ (៨៥៥) ១១ ៨៦៦ ៩៦៦<br>អ៊ីមែលៈ virak.kheng@pafid.org | កម្មវិធី ACCESS 2<br>វេជ្ជបណ្ឌិត ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម<br>ទូរស័ព្ទៈ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីមែលៈ Vivath.Chou@access2cambodia.org |

គម្រោងនេះត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ ដំណាក់កាលទី២ (ACCESS 2) ។
ខែមីនា ឆ្នាំ២០២៤